# ការសំភាសន៍របស់មីង អ៊ុំ ស៊ីណោត

កៈ អ្នកដែរសំភាសន៍គេ ជាង ស៊ីអ៊ារ ខៈ អ្នកដែរអោយគេសំភាសន៍ អ៊ុំ ស៊ីណោត

<u>ការសង្ខេបប្រវត្តិរបស់មីង អ៊ុំ ស៊ីណោត</u>

មីង អ៊ុំ ស៊ីណោត មានអាយុ47ឆ្នាំ នៅក្នុងឆ្នាំ2018។មីង អ៊ុំ ស៊ីណោត មានភេទស្រី។មីង អ៊ុំ ស៊ីណោត មានទីលំនៅបច្ចុប្បន្ននៅភូមិទន្លេបិទ ឃុំទន្លេបិទ ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ។

កៈ ចឹងជាដំបូងខ្ញុំអរគុណច្រើនមីងដែរបានអោយខ្ញុំសំភាសន៍ពីប្រវត្តិរបស់មីង ហើយការសំភាសន៍នេះ ត្រូវបានរៀបចំឡើងដោយសកលវិទ្យាល័យមួយដែរនៅអាមេរិចដែរមានឈ្មោះថាBYU ចឹងហាសមីង ហើយដោយសារតែសកលវិទ្យាល័យមានគោលបំណងចង់រក្សាពីប្រវត្តិប្រជាជនខ្មែរ ដើម្បីទុកអោយកូនចៅជំនាន់ក្រោយៗពួកគាត់បានស្គាល់ពីប្រវត្តិឪពុកម្ដាយនឹងដូនតា ហើយនៅពេលដែរខ្ញុំបានសំភាសន៍មីងហើយខ្ញុំនឹងដាក់ការសំភាសន៍មួយនេះទៅក្នុងវេបសាយរបស់សាលាដែរមានឈ្មោះថា www.cambodianoralhistories.byu.edu ចឹងហាសមីង ចឹងសំរាប់មីងតើមីងយល់ព្រមដើម្បីអោយខ្ញុំសំភាសន៍មួយនឹងទេមីង?

ខៈ ចា៎!មិនអីទេ

កៈ បាទមីងចឹងសំរាប់ខ្ញុំជាអ្នកដែរសំភាសន៍មីងខ្ញុំមានឈ្មោះថាជាង ស៊ីអ៊ារ ហើយថ្ងៃខែដែរខ្ញុំសំភាសន៍ មីងគឺនៅថ្ងៃទី18 ខែ2 ឆ្នាំ2018 ហើយការសំភាសន៍នេះត្រូវសំភាសន៍នៅភូមិអីមីង?

ខៈ ភូមិទន្លេបិទ

កៈ នៅភូមិទន្លេបិទ ឃុំទន្លេបិទ ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំមីង ចឹងសំរាប់ឈ្មោះពេញរបស់មីងឈ្មោះអី គេដែរមីង?

ខៈ ដាក់ទាំងត្រកូលហោស?

កៈ បាទមីងដាក់ទាំងត្រកូលដែរនឹងមីង?

ខ៖  ខ្ញុំឈ្មោះអុំ ស៊ីណោត

ក៖  ឈ្មោះអុំ ស៊ីណោតហោសមីង ចុះមានឈ្មោះហៅក្រៅដែរទេមីង?

ខ៖  ឈ្មោះហៅក្រៅនឹងថាឈ្មោះណោតៗៗនឹង

ក៖  ចុះកាលពីកាលពីក្មេងនឹងមីងមានឈ្មោះហៅអីផ្សេងទៀតទេមីង?

ខ៖  អត់មានឈ្មោះអីទៀតផងនឹង មានឈ្មោះតែមួយនឹង

ក៖  ចុះមីងសព្វថ្ងៃនឹងមីងអាយុប៉ុន្មានដែរមីង?

ខ៖  អាយុ47ឆ្នាំហើយនឹង

ក៖  ចឹងមីងអាយុ47ឆ្នាំ ចុះមីងកើតនៅថ្ងៃខែឆ្នាំណាដែរមីងមានចងចាំទេ?

ខ៖  នៅក្នុងឆ្នាំ1972

ក៖  ចុះនៅថ្ងៃខែមីងមានចងចាំទេ?

ខ៖  បើក្នុងអត្តសញ្ញាប័ណ្ណ គឺនៅថ្ងៃទី15 ខែ7ចឹងហីនេះ

ក៖  ចុះឆ្នាំច័ន្ទគតិមីងមានដឹងថាមីងឆ្នាំអីគេដែរទេមីង?

ខ៖  ខ្ញុំកើតឆ្នាំច

ក៖  អូ៎!មីងឆ្នាំច ណាមីងចុះមីងកើតនៅណាដែរមីង នៅភូមិអី ឃុំអី ស្រុកអីចឹងណាស់មីង?

ខ៖  ខ្ញុំកើតនៅនាងហ៊ីងកំពង់ចាមនឹង

ក៖  នៅភូមិនាងហ៊ីង ចុះឃុំអីគេដែរមីង?

ខ៖  នឹងនៅភូមិសំបូរមាសហើយនឹង ឃុំនាងគង្ហីង

ក៖  ចឹងនៅភូមិសំបូរមាស ឃុំនាងគង្ហីង ស្រុកកំពង់ចាម ខេត្តកំពង់ចាមណាមីង?

ខ៖  ចា៎!មួយនឹងហើយ

ក៖  ចុះមីងមានបងប្អូនចំនួនប៉ុន្មាននាក់ដែរមីង?

ខ៖  បងប្អូនបង្កើតហោស

កៈ បាទបងប្អូនបង្កើតនឹងមីង?

ខៈ មានបងប្អូនចំនួន3នាក់

កៈ ចុះមីងជាកូនទីប៉ុន្មានដែរមីង?

ខៈ ខ្ញុំជាកូនទី2 នឹង

កៈ ចុះមានស្រីប៉ុន្មាននាក់ ហើយប្រុសនឹងប៉ុន្មាននាក់ដែរមីង?

ខៈ មានស្រី2នាក់ នឹងប្រុសម្នាក់

កៈ ចុះមីងអាចប្រាប់ឈ្មោះបងប្អូនរបស់មីងបានទេមីង?

ខៈ ប្រាប់បានតើ!

កៈ គាត់មានឈ្មោះអីគេខ្លះដែរមីង?

ខៈ គាត់មានឈ្មោះបងរិទ្ធិ

កៈ ចុះប្អូនពៅវិញឈ្មោះអីគេដែរមីង?

ខៈ ឈ្មោះស្រីញាញ់

កៈ ចុះមីងធ្លាប់មានអនុស្សាវរីយ៍អីរមួយសាច់រឿងអីកាលពីនៅក្មេងៗហាសដូចថាធ្លាប់ធ្វើអីគេខ្លះដែរជាមួយពួកគាត់ដូចលេងឡឹកបាយឡ នឹងលេងចុយអីចឹងទៅមីង?

ខៈ លេងអីបើដាច់អាពតមកបងប្អូនចែកគ្នាចិញ្ចឹមនឹង បងប្អូនកំព្រាម៉ែឪតាំងពីតូចមកនឹង

កៈ ប៉ុន្តែក្មេងៗនឹងមីងមានធ្លាប់លេងអីជាមួយពួកគាត់ដែរទេមីង?

ខៈ បែកគ្នានៅឆ្ងាយៗពីគ្នានឹង ខ្ញុំនៅកំពង់ចាម ប្អូននៅស្វ្វង បងនៅកំពង់ធំចឹងទៅ

កៈ អូ៎!កើតមកបែកគ្នាចឹងតែម្តងហោសមីង?

ខៈ ចា៎!កើតមកបងប្អូនយកទៅហើយចែកគ្នាចិញ្ចឹមចឹងណាស់

កៈ  អូ៎!បាទមីង
ចុះពេលណុងឪពុកម្ដាយរបស់មីងគាត់លេងនៅជាមួយមីងហើយរឺមួយក៏យ៉ាងម៉េចដែរមីង?

ខៈ  គាត់បានស្លាប់អស់ហើយនឹង ដល់ពេលចឹងនៅក្មេងនឹងបងប្អូនក៏បែកគ្នាដែរនឹង

កៈ  អូ៎!ចឹងហោសមីង?

ខៈ  យើងគ្មានបាននៅជុំគ្នាណា
ដល់ពេលចឹងគ្មានដឹងប្រវត្តិថានៅជាមួយគ្នាយ៉ាងម៉េចផងនឹង

កៈ  ចឹងមានន័យថាកាលពីនៅតូចនឹង មីងគ្មានដឹងថាមានបានលេងអីជាមួយបងប្អូនទេដោយសារតែបែកគ្នាអស់ហើយណមីង?

ខៈ  អត់ដឹងទេពីព្រោះបែកគ្នាអស់ហើយនឹង
ដល់ពេលឥឡូវនឹងនៅតែបែកគ្នានៅរៀងខ្លួនដដែរនឹង

កៈ  អូ៎!ចឹងហោសមីង?

ខៈ  គេមានប្ដីមានកូនរៀងខ្លួនអស់ហើយនឹង

កៈ  ចុះបងប្អូនរបស់មីងនឹងសព្វថ្ងៃគាត់នៅណាដែរទៅមីង?

ខៈ  នៅប៉ោយប៉ែតមួយបងប្រុស នឹងប្អូនស្រីនឹងនៅត្រពាំងប្រាសាទ

កៈ  ប៉ុន្តែពួកគាត់ធ្វើអីគេដែរនៅណុងមីង?

ខៈ  គេលក់ដូរឥវ៉ាន់នៅក្នុងផ្សារអីនឹងហាស

កៈ  នឹងអ្នកនៅប៉ោយប៉ែតណមីង?

ខៈ  ទេអ្នកនៅត្រពាំងប្រាសាទ អ្នកនៅប៉ោយប៉ែតនឹងធ្វើអ្នកលាងឡានអីចឹងទៅណាស់

កៈ  អូ៎!ពួកគាត់នៅឆ្ងាយៗពីមីងហោសមីង

ខៈ  ចា៎!អត់មាននៅជុំគ្នាទេ

កៈ  ចឹងត្រពាំងប្រាសាទនឹងប៉ោយប៉ែតនឹង នៅជិតគ្នានឹងមីង?

ខ៖ ចា៎!នៅជិតគ្នានឹងណាស់

ក៖ ចឹងមានន័យថាឆ្ងាយតែមីងមួយទេ?

ខ៖ នឹងហើយឆ្ងាយតែខ្ញុំមួយនឹង

ក៖ អូ៎!បាទមីងចុះឪពុករបស់មីងគាត់មានឈ្មោះអីគេដែរមីង?

ខ៖ គាត់មានឈ្មោះអ៊ុំ នាត គាត់ពីដើមនឹងគាត់ជាគ្រូបង្រៀនដែរតើ!

ក៖ គាត់ជាគ្រូបង្រៀនណាមីង ចុះគាត់កើតនៅថ្ងៃខែឆ្នាំណាមីងមានដឹងទេ?

ខ៖ អូយអត់ចាំទេ បើនៅតឡូវនឹងប្រហែលជាអាយុហុកជាងហើយនឹង

ក៖ ចុះគាត់កើតនៅឆ្នាំណាមីងមានដឹងអត់?

ខ៖ ខ្ញុំអត់ដឹងសោះ ខ្ញុំអត់ដឹងប្រវត្តិម៉ែឪទាំងអស់នឹង

ក៖ ដោយសារតែគាត់បានស្លាប់តាំងពីមីងនៅតូចៗណាមីង?

ខ៖ គាត់ស្លាប់តាំងពីជំនាន់អាពត បែកអាពតអស់8-9ឆ្នាំនឹងគាត់ស្លាប់បាត់ហើយនឹង

ក៖ អូ៎!បាទមីងចឹងហោស?

ខ៖ ដល់ពេលចឹងមិនបានដឹងពីប្រវត្តិរបស់គាត់បន្តិចសោះ

ក៖ ចុះម្ដាយរបស់មីងគាត់មានឈ្មោះអីគេដែរមីង?

ខ៖ ម្ដាយរបស់ខ្ញុំនឹងគាត់មានឈ្មោះ ស្រ៊ុន អេងឆាយ

ក៖ ប៉ុន្តែគាត់កើតនៅណាដែរមីងមានដឹងទេ?

ខ៖ ម្ដាយរបស់ខ្ញុំនឹងគាត់កើតនៅកោះកុក

ក៖ អូ៎!គាត់កើតនៅកោះកុកហោសមីង?

ខ៖ ចា៎!ប៉ុន្តែមិនដឹងថាគាត់ឆ្នាំអីផងនឹង

ក៖ ប៉ុន្តែឪពុករបស់មីងនឹងគាត់កើតនៅណាដែរមីង?

ខ៖ គាត់កើតនៅនាងហ៊ីងនឹងដែរ ស្រុកកំណើតរបស់គាត់អ្នកនាងហ៊ីងប៉ារបស់ខ្ញុំនឹង

កៈ
ចឹងមានន័យថាពេលដែរមីងកើតមកនឹងមីងមកនៅខាងឪពុករបស់មីងតែម្តងហោសមីង?

ខៈ ទេមកនៅខាងម្តាយតើ ដូចថាខ្ញុំមកនៅកោះចឹងហើយប្អូនគេនៅស្ទឹងណោះ ហើយបងនៅកំពង់ធំ ហើយគេចែកគ្នាចិញ្ចឹមចឹងណាស់

កៈ អូ៎!បាទមីងចឹង?

ខៈ
រួចទៅគេបានរៀបការចឹងទៅគេនៅតែនៅបែកគ្នាចឹងដដែរនឹងណាស់ដល់ពេលចឹងវាគ្មានប្រវត្តិ របស់បងប្អូនសោះនឹង

កៈ បាទមីង ចុះឪពុករបស់មីងគាត់ធ្វើអីគេដែរសំរាប់ចិញ្ចឹមជីវិតដែរមីង?

ខៈ ពីណាគេដែរ?

កៈ ឪពុករបស់មីងហាស?

ខៈ គាត់ជាគ្រូបង្រៀនដែរតើពីដើមនឹង
ខ្ញុំដឹងពីយាយប្រាប់ទេណាស់តែខ្ញុំមិនសូវស្គាល់គាត់ច្បាស់ដែរ
នឹងមិនដឹងពីប្រវត្តិរបស់គាត់ទេ

កៈ ចុះឪពុករបស់មីងគាត់ស្លូតរឺមួយក៏កាចដែរមីង?

ខៈ កាត់ស្លូតដែរតើ!ប៉ារបស់ខ្ញុំនឹង

កៈ អូ៎!បាទមីង ចុះម្តាយរបស់មីងគាត់ធ្វើអីគេដែរសំរាប់ចិញ្ចឹមជីវិតដែរមីង?

ខៈ គាត់នៅផ្ទះមើលកូនអីនឹងម្តាយរបស់ខ្ញុំចិញ្ចឹម

កៈ ចុះកាត់ស្លូតរឺមួយក៏កាចដែរមីង?

ខៈ ខ្ញុំមិសូវច្បាស់ដែរនឹងរឿងនឹង

កៈ ដូចជាមីងនៅក្មេងៗណាមីង?

ខៈ គាត់មិនសូវកាចដែរទេគាត់ស្លូតដែរនឹង

កៈ ចុះមីងមានចងចាំសាច់រឿងកាលពីមីងនៅជាមួយពួកគាត់ដែរទេ?

ខៈ អត់ចងចាំទេ

កៈ ថាមីងមានធ្លាប់ធ្វើអីជាមួយពួកគាត់ដែរចឹងណាស់?

ខៈ ជាមួយប៉ារបស់ខ្ញុំនឹង?

កៈ ជាមួយឪពុកនឹងម្ដាយហាស កាលពីមីងនៅជាមួយពួកគាត់ហាស?

ខៈ ម៉ាក់របស់ខ្ញុំនៅមើលកូនចឹងទៅមានបងប្អូននៅមើលថៃចឹងទៅ
គាត់មិនសូវអីទេគាត់នៅតែផ្ទះនឹង ម្ដាយរបស់ខ្ញុំនឹង
ហើយយាយតារបស់ខ្ញុំនឹងគាត់ចេះតែចិញ្ចឹមចៅចឹងទៅ

កៈ បាទចឹងហោសមីង?

ខៈ គាត់អាចារ្យចឹងគាត់មកពីបុណ្យទានចឹងគាត់ច្រើនតែអោយនុំចៅ
គាត់ច្រើនតែយកចៅនៅជាមួយ ចឹងទៅណាស់យាយតានឹងណាស់

កៈ អូ៎!ទាំងយាយទាំងតានឹងហោសមីង?

ខៈ គ្រាន់តែថាម៉េចទៀតនឹងខ្ញុំមិនសូវច្បាស់ដែរមុខមាត់អីនឹង ខ្ញុំនៅតូចពេក

កៈ មីងកើតទាន់ដែរតែមីងនៅតូចណាមីង?

ខៈ ចា៎!នឹងហើយយើងកើតទាន់យាយតាកុងដែរប៉ុន្តែគ្រាន់តែថាយើងវានៅតូចពេកនឹង

កៈ ចុះឪពុករបស់មីងនឹងគាត់មានធ្លាប់ប្រាប់ពីប្រវត្តិកាលពីគាត់នៅក្មេងទៅមីងដែរទេ?

ខៈ ខ្ញុំមិនបានដឹងទាំងអស់នឹង

កៈ ប៉ុន្តែយាយតារបស់មីងគាត់មានធ្លាប់ប្រាប់ពីឪពុករបស់មីងដែរទេ?

ខៈ អត់មានទេ

កៈ អត់ទេណាមីង ចុះម្ដាយរបស់មីងវិញមានដឹងពីប្រវត្តិកាលពីគាត់នៅក្មេងទៅមីងដែរទេ?

ខៈ អត់ដឹងដែរនឹង
ដឹងគ្រាន់តែថាប៉ារបស់ខ្ញុំនឹងគាត់ធ្វើជាគ្រូបង្រៀនកាលពីដើមចឹងទៅដូចថាបងប្អូន

ខាងម្ដាយរបស់ខ្ញុំគាត់ក្រចឹងទៅគាត់យកទៅចិញ្ចឹមទាំងអស់នឹង
ប៉ុន្តែមានរឿងអីផ្សេងទៀតនឹងខ្ញុំមិនសូវ ដឹងដែរនឹង

កៈ ចុះយាយតាខាងឪពុកមីងមានស្គាល់ឈ្មោះគាត់ដែរទេ?

ខៈ ខ្ញុំស្គាល់តើ!

កៈ ចុះយាយតាខាងឪពុកនឹងគាត់មានឈ្មោះអីគេដែរមីង?

ខៈ ចាំមើលតារបស់ខ្ញុំនឹងឈ្មោះតាពៃ ហើយយាយរបស់ខ្ញុំនឹងឈ្មោះយាយនាង

កៈ ចុះគាត់កើតនៅណាដែរមីងមានដឹងទេ?

ខៈ ខ្ញុំមិនដឹងពីប្រវត្តិរបស់គាត់សោះតែម្តងនឹង

កៈ ចុះយាយតាខាងម្តាយមីងមានស្គាល់ឈ្មោះគាត់ដែរទេ?

ខៈ គាត់មានឈ្មោះតាស្រ៊ុន នឹងយាយស៊ាន់

កៈ ចុះចឹងគាត់កើតនៅណាក៏មីងមិនដឹងដូចគ្នា?

ខៈ ខ្ញុំមិនដឹងដែរនឹង

កៈ ចុះមីងមកនៅខេត្តត្បូងឃ្មុំនឹងយូរនៅមីង?

ខៈ ខ្ញុំមកនៅជាង10ឆ្នាំហើយនឹងខ្ញុំមករស់នៅនឹង

កៈ ចុះមីងមានសាច់ញ្ញាតិ រឺមួយក៏សូនថៅណាដែរទៅរស់នៅក្រៅប្រទេសទេ?

ខៈ អត់មានទេ

កៈ នៅវៀតណាម ថៃអីក៏មិនមានដែរ?

ខៈ អត់មានទេមានតែនៅខាងណាទេ

កៈ ប៉ុន្តែបងប្អូនអីមានដែរតើហីមីង?

ខៈ មាននៅកាណាដាបងប្អូនជីដូនមួយអីនឹងណាស់

កៈ ប៉ុន្តែគាត់បានធ្វើអីគេនៅកាណាដានឹងមីង?

ខ៖
ខ្ញុំមិនបានដឹងទេគេនៅណុងដូចថាពេលដែរគេមកគេរាប់អានតែបងប្អូនគេណុងយើងបងប្អូនដែរ ប៉ុន្តែគេមិនសូវនិយាយអីផង

ក៖ ចឹងគេមិនសូវទេណាមីង?

ខ៖ គេមិនសូវជាទំនាក់ទំនងអីទេ

ក៖ ចុះស្វាមីរបស់មីងគាត់មានឈ្មោះអីគេដែរមីង?

ខ៖ ស្វាមីរបស់ខ្ញុំឪអាតុលានឹងហោស?

ក៖ បាទមីងមានឈ្មោះអីគេដែរមីង?

ខ៖ គាត់មានឈ្មោះសុខ ជាប៉ុន្តែខ្ញុំបែកគ្នាហើយនឹងចឹងមិនបាច់ដាក់ទេហី

ក៖ អត់មានបញ្ហាអីទេមីង

ខ៖ យើងបែកគ្នាហើយប៉ុន្តែគ្រាន់តែកូនចៅគេទៅនៅជាមួយឪពុកគេចឹងទៅណាស់ ហើយខ្ញុំនឹងដូចថាមកយកប្តីក្រោយនឹងបានកូនមួយអីចឹងទៅណាស់

ក៖ អូ៎!វាចឹងហោសមីង?

ខ៖ នឹងហើយលក្ខណះវាបែកខ្វែកគ្នាអីចឹងទៅណាស់

ក៖ គ្រាន់តែចង់សួរមីងថាមីងការនៅថ្ងៃខែឆ្នាំណាអីចឹងណាស់?

ខ៖ ការជាមួយឪវានឹងនៅឆ្នាំ1989នឹង

ក៖ ចឹងមីងការនៅឆ្នាំ1989នឹង ចុះថ្ងៃទី រឺមួយក៏ខែអីមីងមានចងចាំអត់មីង?

ខ៖ អត់ចងចាំដែរនឹងបាត់អស់ហើយនឹង

ក៖ អូ៎!ចឹងមីងមិនចងចាំទេ?

ខ៖ គ្រាន់ប្រវត្តិរូបទេកាលណុង

ក៖ ចុះនៅពេលដែរមីងរៀបអាពាហ៍ពិពាហ៍នឹងគិតថាឪពុកម្តាយជាអ្នករៀបអោយ រឺក៏មីងជាអ្នករៀបដោយខ្លួនឯងដែរ?

ខ៖ ម្តាយធំគាត់ជាអ្នករៀបអោយ

ក៖ ប៉ុន្តែពេលណុងដូចជាមានជាជំនូនអត់មីង?

ខ៖ មានដែរតើ!

ក៖ ប៉ុន្តែកាលណុងមានជាប៉ុន្មានដែរមីងអាចប្រាប់ខ្ញុំបានដែរទេ?

ខ៖ កាលណុងគេជូនជាប៉ុន្មានទេដូចជា7ជីចឹងហើយនឹងកាលការនឹង

ក៖ អ្ហូ!ចឹងពូអោយមីង7ជីណាមីង?

ខ៖ នឹងហើយគិតមាសដូចជា7ជីនឹងហើយ
ឆ្នាំ1989កាលណុងគេគ្រាន់តែប្រើមាសចាយចឹងណាស់

ក៖ ចុះមីងមានចេះភាសាខ្មែរដែរទេ?

ខ៖ ខ្ញុំចេះតែភាសាខ្មែរនឹង

ក៖ ប៉ុន្តែមីងធ្លាប់បានរៀនដែរទេ?

ខ៖ ខ្ញុំរៀនបានថ្នាក់ទី4នឹង

ក៖ មីងរៀនបានថ្នាក់ទី4ណាមីង ចុះកាលពីមីងរៀននឹងតើមីងរៀននៅសាលាណាដែរមីង?

ខ៖ កាលពីខ្ញុំរៀននឹងសាលានឹងនៅកោះហោស រៀននៅកោះសូទិនហោស

ក៖ អ្ហូ!រៀននៅកោះសូទិនហោសមីង?

ខ៖ រៀននៅចុងកោះសូទិនហោស

ក៖ ចុះសាលានឹងមានឈ្មោះអីគេដែរមីងមានចងចាំទេ?

ខ៖ គេដាក់សាលាចុងកោះសូទិនចឹងហើយនឹង

ក៖ ឈ្មោះសាលាចឹងតែម្តងហោសមីង?

ខ៖ គេដាក់បឋមសិក្សាកោះសូទិននឹង

ក៖ ប៉ុន្តែមីងមានដូរសាលាផ្សេងអីទៀតទេ រឺមួយមីងរៀនតែនៅសាលាណុងទេ?

ខៈ  អត់ទេរៀនបានតែថ្នាក់ទី4នឹងដល់ពេលហើយឈប់ទៅមានប្ដីអីទៅនឹង

កៈ  អ៎ូ!បាទមីង ចុះមីងមានចេះភាសាអីក្រៅពីភាសាខ្មែរដែរទេមីង ដូចជាភាសាថៃ ភាសាអង់គ្លេស ភាសាអីចឹងទៅណាស់មីង?

ខៈ  អត់ចេះផងនឹងអត់បានទៅរៀនភាសាអង់គ្លេស រឺមួយក៏ចិនអីអត់មានទេចេះតែខ្មែរសុទ្ធនឹង

កៈ  បាទមីង ចុះមីងធ្លាប់មិត្តភក្តិណាដែរធំធាត់មកជាមួយគ្នាវិញអីទេមីង?

ខៈ  អត់ទេគ្មានមិត្តភក្តិអីផងនឹង

កៈ  លក្ខណៈកាលពីមីងនៅរៀនអីនឹងធ្លប់មានមិត្តភក្តិអីទេ?

ខៈ  កាលណុងមានប៉ុន្តែដូចថាគេមានប្ដីអីចឹងទៅក៏បែកខ្ញែកគ្នាទៅផ្សេងៗទៅលែងបានរាប់អានគ្នាចឹងទៅណាស់

កៈ  អ៎ូ!បាទមីង ចុះមីងអាចប្រាប់ឈ្មោះមិត្តភក្តិរបស់មីងមួយចំនួនដែរមីងគិតថាមីងចងចាំបានទេ?

ខៈ  មានឈ្មោះធីតា

កៈ  មានឈ្មោះអីផ្សេងទៀតទេមីង?

ខៈ  ប្រាប់ឈ្មោះប៉ុន្មាននាក់ដែរទៅ?

កៈ  មានប៉ុន្មាននាក់ដែរមីងគិតថាមីងចងចាំដូចជា2-3នាក់អីចឹងទៅ?

ខៈ  គ្មានចងចាំទេត្រកូលគេក៏មីងមិនបានដឹងដែរនឹង

កៈ  អ៎ូ!ចឹងហោសមីង?

ខៈ  ខ្ញុំបានស្គាល់តែឈ្មោះគេនឹង

កៈ  បាទមីង ចុះមីងគិតថាកាលពីនៅក្មេងនឹងតើ មីងធ្លាប់មានអនុស្សាវរីយ៍អីជាមួយគ្នាដែរទេមីង?

ខ៖ មានដែរតើ ធ្លាប់លេងអីៗលក្ខណៈថាចូលឆ្នាំអីចឹងទៅលេងអីលេងទាំងអស់គ្នា មានអីហូបចឹងហូប ទាំងអស់គ្នាចឹងទៅណាស់មានតែប៉ុណ្ណឹង

ក៖ ប៉ុន្តែធ្លាប់ទៅធ្វើការនៅវាលស្រែអីទេមីង លក្ខណៈថាជាមួយមិត្តភក្តិរបស់មីងចឹងណាស់?

ខ៖ ទៅចំការទៅដាំថ្នាំអីមានតែចឹង

ក៖ អូបាទមីងចុះមីងធ្លាប់ទៅធ្វើការងារនៅវាលស្រែដែរទេ លក្ខណៈថាជាស្រែចំការអីចឹងមីងធ្លាប់ទេ?

ខ៖ ធ្លាប់ដែរតើ ទៅចំការដាំថ្នាំខ្មែរនឹងកាលណុង

ក៖ ចុះមីងមានធ្លាប់បង្កើតមុខរបរអាជីកម្មអីទេមីង?

ខ៖ មានដែរតើ ពេលដែរមានប្តីទៅចេះលក់បង្អែម លក់ទឹកអំពៅអីចឹងទៅសព្វថ្ងៃនឹងណាស់

ក៖ ប៉ុន្តែមីងមានធ្លាប់ចិញ្ចឹមសត្វទេមីងលក្ខណៈដូចជាចិញ្ចឹមគោ ចិញ្ចឹមក្របីអីចឹង?

ខ៖ អត់មានទេ

ក៖ ចិញ្ចឹមជ្រូក មាន់ ទាអីក៏អត់ដែរ?

ខ៖ អត់មានទាំងអស់នឹង

ក៖ ចុះមីងគិតថាជីវិតរបស់មីងមានការផ្លាស់ប្តូរអីគេខ្លះដែរមីងតាំងបីក្មេងរហូតមកដល់ពេលនេះនឹង?

ខ៖ ផ្លាស់ប្តូរដូចថាសព្វថ្ងៃនឹងទៅជួលផ្ទះគេលក់អីៗតាមចិញ្ចើមផ្លូចចឹងវេទនាចឹងទៅណាស់

ក៖ អូ!ចឹងហោសមីង?

ខ៖ ស្ទូម្បីតែរកលុយនឹងចិញ្ចឹមកូនមិនចង់រស់ផងវាពិបាកចឹងណាស់

ក៖ ចុះទាំងជីវភាព ទាំងសុខភាពមីងគិតថាមានការផ្លាស់ប្តូរអីគេខ្លះដែរទៅមីង?

ខ៖  ផ្លាស់ប្ដូរយ៉ាងម៉េចទៅដូចថាឈឺអីនឹងហោស?

ក៖  បាទមីងទាំងសុខភាព ទាំងជីវភាពអីចឹងណាស់?

ខ៖  ឈឺតើ ឧស្សាហ៍លេបថ្នាំរហូតដែរនឹង
ចេះតែធ្វើទុករុយក៏ចឹងទៅឡើងជាតិអាស៊ីតអីចឹងទៅ

ក៖  ចុះម្ហូបអីគេដែរមីងចូលចិត្ត?

ខ៖  ចូលចិត្តតែម្ហូបខ្មែរនឹង មានតែម្ជូរ នឹងប្រហើរនឹង

ក៖  ចុះកកូរ ការី ឆា ចៀនអីមីងមិនសូវចូលចិត្តទេ?

ខ៖  មិនសូវចូលចិត្តទេសាច់អីទេនឹងហោស ចូលចិត្តតែត្រីនឹង

ក៖  ចុះតាំងពីក្មេងហាសមីងចូលចិត្តលេងល្បែងប្រជាប្រិយ៍អីគេដែរមីង?

ខ៖  ខ្ញុំចូលចិត្តបោះអង្គុ ចោលឈូងអីនឹងដែរខ្ញុំចូលចិត្ត

ក៖  ទាញព្រាតលាក់កន្សែងអីនឹងហោសមីង?

ខ៖  ចា៎!នឹងដែរចូលចិត្តទាញព្រាតអីនឹង

ក៖  ប៉ុន្តែមីងចេះច្រៀងដែរទេមីង?

ខ៖  អត់ចេះទេចេះតែរាំនឹង

ក៖  អូ៎!មីងចេះតែរាំទេហោសមីង ចឹងមានន័យថាមីងចេះលេងល្បែងរាំទៀតនឹង?

ខ៖  នឹងហើយ រាំចូលចិត្តបើថាអីនឹងចេះរាំទៀត
ទៅហាត់ប្រាណទៅយូរៗគេបង្រៀនរាំទៅចេះហើយនឹង ណាស់

ក៖  អូ៎!ចឹងមានន័យថាមីងទៅរៀនរាំហាត់ប្រាណណាមីង?

ខ៖
ទៅហាត់ប្រាណរាំលេងរាល់ល្ងាចនៅក្រោមស្ពាននឹងអោយតែម៉ោង5នឹងចាប់ផ្តើមហើយនឹង

ក៖  ប៉ុន្តែមីងចូលចិត្តស្ដាប់បទចំរៀងទេ?

ខ៖ ខ្ញុំចូលចិត្តដែរតើ!នឹង

ក៖ លក្ខណះថាជាបទសម័យរឺមួយក៏បទបុរាណដែរមីង?

ខ៖ បទបុរាណនឹងចូលចិត្តស្តាប់នឹង

ក៖ ចុះមីងមាននរណាគេនៅក្នុនងក្រុមគ្រួសារ
រឺមួយក៏បងប្អូនដែរចេះលេងឧបករណ៍ភ្លេងដែរទេមីង?

ខ៖ អត់មានផងនឹង

ក៖ ទាំងភ្លេងខ្មែរ ភ្លេងពិនពាត ភ្លេងសៀមអីក៏មីងមិនចេះដែរណាមីង?

ខ៖ អត់ចេះទេ

ក៖
ចុះមីងផ្ទះរបស់មីងមានលក្ខណះបែបណាដែរមីងតាំងពីក្មេងរហូតមកដល់ពេលនេះហាស
?

ខ៖ នឹងផ្ទះនឹងទើបតែទិញគេនឹង

ក៖ ចុះផ្ទះរបស់មីងមានលក្ខណះបែបណាដែរពីក្មេងមីង?

ខ៖ ពីក្មេងខ្ញុំមានផ្ទះមកពីណាបើខ្ញុំនៅជាមួយម្តាយមីង
ម្តាយធំនឹងខ្ញុំនៅកំព្រាចឹងខ្ញុំមានផ្ទះណាខ្លួនឯងដែរទៅ

ក៖ អូ៎!ចឹងទេឥឡូវនឹងបានមីងមានផ្ទះ?

ខ៖ នឹងហើយដល់ពេលចឹងទៅបានយើងខំរកដោយទឹកញើសឈាមខំរក4-
5ឆ្នាំនឹងទើបតែទិញបាននឹង បានតែប៉ុណ្ណឹង

ក៖ អូ៎!នឹងផ្ទះរបស់មីងតែម្តង?

ខ៖ នឹងហើយផ្ទះឈើកញ្ចាស់នឹង

ក៖ ប៉ុន្តែផ្ទះមួយនឹងដូចជាមីងទិញពីគេនឹងមីងជាអ្នកធ្វើរឺក៏មីងគេស្រាប់តែម្តង

ខ៖ ខ្ញុំទិញស្រាប់នឹង ខ្ញុំទិញតពីគេនឹង

កៈ ចឹងពេលទិញនឹងមីងមិនដឹងថាផ្ទះមួយនឹងគេធ្វើមកពីស្អីគេខ្លះទេណាមីង?

ខៈ ចាំ!មិនដឹងទេ

កៈ ចុះមានជំនាញអីដែរមីងគិតថាមីងចេះស្ទាត់ជំនាញដែរទេមីង?

ខៈ ជំនាញខាងអីគេ?

កៈ ទាំងខាងលក់ដូរអីចឹង?

ខៈ លក់ដូរជំនាញខាងអីទូទៅនឹងដូចថាគ្រឿងហូប នឹងគ្រឿងស៊ីអីនឹងចេះ

កៈ ចុះឪពុកម្ដាយរបស់មីងគាត់មានធ្លាប់នបង្រៀនពីជំនាញអីទៅមីងដែរទេ
ដូចថាវេញវល្លិ៍ ធ្វើល្អី កក្កូរស្កត្នោត អីមានទេ?

ខៈ បើមិនដឹងប្រវត្តិរបស់គាត់ផងនឹង

កៈ ប៉ុន្តែពឪពុកម្ដាយរបស់មីង រឺយាយតារបស់មីងនឹងធ្លាប់បង្រៀនអីទៅមីងដែរទេ?

ខៈ
អត់មានទេពេលដែរដឹងក្ដីឡើងនឹងគាត់ចាស់ៗអស់ហើយនឹងគាត់គ្មានបង្រៀនអីផងនឹង

កៈ អូ៎!ចឹងហោសមីង?

ខៈ ចឹងដូចថាខ្លួនឯងនឹងរស់ដោយខ្លួនឯងនឹងណាស់
ខ្ញុំនិយាយចឹងគ្មានបងប្អូនណាជួយផងដូលខ្លួនឯង នឹងងើបខ្លួនឯងនឹង

កៈ ចឹងមានន័យថាមីងធ្វើអីដោយខ្លួនឯងចឹងទៅ?

ខៈ ដូចថាពឹងប្ដីទៅចាប់ដៃគ្នារកស៊ីចឹងទៅ
ចេះតែរកស៊ីចឹងទៅរកលិចរកកើតចឹងទៅទំរាំបានជ្រកនឹង មានតែប៉ុណ្ណឹងប្រវត្តិរបស់ខ្ញុំ

កៈ ចឹងមានន័យថាអត់សូវស្រួលទេណាមីង?

ខៈ ចាំ!មានចឹង

កៈ ចុះមីងអាចប្រាប់ខ្ញុំបានទេថាពេលណាដែរមីងគិតថាជាពេលដែរមីងលំបាកដែរ
ចាប់ពីក្មេងរហូតមកដល់ឥឡូវនឹងណាស់?

ខ៖  ពិបាកដែរតើ យកប្តីក៏ពិបាកដែរនឹង

ក៖  ចុះកាលពីមីងនៅក្មេងនឹងតើមីងគិតថាមីងលំបាកអីគេខ្លះដែរទៅមីង?

ខ៖  លំបាកកំសត់យើងវាក្រចឹងទៅណាស់
រួចទៅដល់ពេលធំឡើងបានរៀនតិចហើយឆាប់យកប្តីទៀត
ដល់ពេលចឹងយកប្តីបានកូន3នាក់នឹងក៏លែងគ្នាដោយសារតែយើងពិបាករឿងរកស៊ីអីចឹង
ទៅណាស់

ក៖  អូ!បាទមីងបាទ?

ខ៖  យើងបែកបាក់គ្នាអីចឹងទៅ

ក៖  ចុះពេលដែរជំនាញពលពតនឹងគេអោយមីងធ្វើអីគេខ្លះដែរទៅមីង?

ខ៖  អត់បានធ្វើអីផងត្រូវលើកអាចម៍គោដែរប៉ុន្តែនៅស្ទើកាលណុង
ហើយមិនទាន់បានលើកអីផងនឹង ក៏ដាច់អាពតទៅនឹង

ក៖  ប៉ុន្តែពេលណុងគេជំលាសមីងទៅណាដែរទៅ?

ខ៖  គេជំលាសខ្ញុំទៅស្ទូងហោស

ក៖  គេជំលាសទៅស្ទូងគេជំលាសមីងទៅតែម្នាក់ឯងរឺយ៉ាងម៉េចមីង?

ខ៖
ទៅជាមួយម្តាយឪពុកនឹងណាស់ហើយដល់ពេលនឹងទៅគេដឹងថាម្តាយឪពុករបស់យើងធ្វើ
ជាគ្រូចឹង ទៅដល់ហើយគេរកសំលាប់ចោលចឹងទៅ
អ្នកស្រុកនឹងគេអាណិតកូននឹងក៏ចែកគ្នាលាក់ចឹងទៅ

ក៖  អូ!បងប្អូនរបស់មីងនឹងហោស?

ខ៖  នឹងហើយហើយអ្នកស្រុកនឹងក៏ជួយលាក់ចឹងទៅទាំងម្តាយឪពុកនឹង
ដល់ពេលដែរទៅធ្វើការចឹងទៅ ក៏បានម្ហូបបានបាយចឹងទៅ
គាត់អោយតែកូនញាំុចឹងទៅគាត់សុខចិត្តដេកអត់ស្លាប់ចឹងទៅណាស់

ក៖  អូ!គេងដេកអត់ស្លាប់រឺមួយក៏អាពតយកទៅសំលាប់ចោលដែរមីង?

ខ៖
អាពតប្រុងយកទៅសំលាប់ចោលប៉ុន្មានដងហើយប៉ុន្តែអ្នកស្រុកចេះតែយកទៅលាក់ចឹងទៅ
បានតែបាយបន្តិចៗទៅអោយតែកូនរស់គាត់សុខចិត្តដេកអត់បាយគាត់សុខចិត្តស្លាប់ណាស់

ក៖ ប៉ុន្តែម្ដាយឪពុកគាត់មិនបានប្រាប់ថាគាត់ជាគ្រូបង្រៀនទេ?

ខ៖ អត់ប្រាប់ទេគេស្រាវជ្រាវដឹងប្រវត្តិរបស់គាត់ធ្វើជាគ្រូបង្រៀននៅនាងហ៊ឹងអីចឹងណាស់

ក៖ បាទចឹងហោសមីង?

ខ៖
ហើយអ្នកស្រុកគេអាណិតចឹងទៅគេចេះតែលាក់និយាយទៅគាត់ស្លាប់ដោយសារតែអត់បាយតែម្ដង

ក៖ ទាំងម្ដាយនឹងទាំងឪពុកនឹង?

ខ៖ ចា៎!នឹងជំនាន់អាពត

ក៖ ចុះបងប្អូនរបស់មីងនឹងគាត់ធ្វើអីគេដែរទៅមីង?

ខ៖ បងរបស់ខ្ញុំនឹងវាបានលើកអាចម៍គោអីដែរនឹង
គ្រាន់តែវាមិននៅជុំគ្នាបងប្អូន3នាក់នឹងហោស

ក៖ បាទមីងនៅស្វងកំពង់ធំនឹងហោសមីង?

ខ៖ ចា៎!នឹងណុង

ក៖ ហើយនៅពេលដែរដាច់ពលពតនឹងមីងបានធ្វើអីទៀតទៅមីង?

ខ៖
ពេលដែរដាច់អាពតចឹងនៅជាមួយម្ដាយធំចឹងទៅគេចិញ្ចឹមក៏ដាំថ្នាំអីជាមួយគាត់ចឹងទៅណាស់ ទៅធ្វើចំការចឹងទៅនឹងបានទៅរៀនអីចឹង
ហើយក៏មានម្ដាយធំមួយទៀតក៏អាណិតហៅមកនៅកំពង់ចាម
នឹងក៏បានរៀបការអីអោយនឹងហាស

កៈ អ៎ូ!ចឹងមីងក៏ការទៅ?

ខៈ ចុះកាលណុងអាយុ18-19ឆ្នាំនឹងក៏បានរៀបការចឹងទៅ

កៈ ចុះកាលពីពេលដាច់ពលពតនឹងមីងពេលណុងក៏ចូលជំនាន់ខ្មែរក្រហមមែនទេមីង?

ខៈ អត់ដឹងទេមិនដឹងថាខ្មែរក្រហមរឺអីមិនដឹងទាំងអស់នឹង

កៈ
មីងគ្រាន់តែដឹងថាពេលដាច់ពលពតចឹងម្ដាយធំរបស់មីងអោយមីងរៀបការមែនទេមីង?

ខៈ ចា៎!នឹងហើយ

កៈ ចឹងមានន័យថាមីងយកប្ដីអាយុប៉ុន្មានដែរមីង?

ខៈ ខ្ញុំយកនៅអាយុ19ឆ្នាំ

កៈ មីងយកអាយុ19ឆ្នាំ នឹងរហូតមីងមានកូន3នាក់នឹងទៅ?

ខៈ ចា៎!រហូតដល់ពេលដែរខ្ញុំមានកូន3នាក់នឹងបានខ្ញុំបែកគ្នានឹង

កៈ ដល់ពេលចឹងមីងក៏បានប្ដីមួយទៀតទៅ?

ខៈ នឹងហើយរហូតមីងយកប្ដីមួយទៀតបានកូនមួយដែរស្រី
ហើយរាល់ថ្ងៃនឹងខំរកលុយដើម្បីចិញ្ចឹមកូន ស្រីនឹងណាស់

កៈ ប៉ុន្តែមីងគិតថាមីងឆ្លងកាត់ឧបសគ្គរឺ ការលំបាកមួយនឹងដោយរបៀបណាដែរមីង?

ខៈ លក្ខណះថាវេទនាដូចថាដួលខ្លួនឯងនឹងងើបខ្លួនឯងចឹងទៅ
ខ្វះមុខខ្វះក្រោយសព្វបែបយ៉ាងដែរនឹង

កៈ បាទមីង
ចុះមីងកិតថាពេលណាដែរមីងគិតថាជាពេលដែរសប្បាយជាងគេនៅក្នុងឆាកជីវិតរបស់មីងដែរនឹង?

ខៈ ពេលមានលុយសប្បាយហើយឥឡូវនឹង

កៈ ពេលដែរមីងមានលុយ?

ខ៖  ប៉ុន្តែឥឡូវនឹងអត់លុយចឹងអត់សប្បាយទេ

ក៖  នឹងជួបជុំបងប្អូនដែរណាមីង ដែរធ្វើអោយមីងសប្បាយ?

ខ៖  ចា៎!នឹងហើយសំខាន់អោយតែខ្ញុំរកលុយបានសប្បាយហើយនឹង

ក៖  ចុះកាលពីក្មេងមីងធ្លាប់មានក្តីស្រម៉ៃថាពេលដែរធំឡើងនឹងមីងចង់ធ្វើអីទេមីង?

ខ៖  គិតទៅគឺខំរកស៊ីដើម្បីខ្លួននឹង ខំរកស៊ីធ្វើម៉េចអោយបានលុយចេះតែដេកគិតស្រម៉ៃ ប៉ុន្តែដូចជាវាមិនបានជោគជ័យបានតែមួយត្រឹមៗនឹង

ក៖  ប៉ុន្តែកាលពីក្មេងនឹងថាធំឡើងនឹងមីងចង់ធ្វើជាគ្រូបង្រៀន គ្រូពេទ្យអី ប៉ូលីសនឹង?

ខ៖  ខ្ញុំមិនដែរប្រាថ្នាទេ ពីព្រោះអីរៀនបានតិចចឹងអត់ប្រាថ្នាអត់ទេ បើរៀនបានតិចចុះបងប្អូនក្រចឹងរៀន បានតែថ្នាក់ទី4ទេចឹងយំនឹងអត់លុយរៀនទេ

ក៖  មីងជាអ្នកឈប់ខ្លួនឯងរឺនរណាគេជាអ្នកអោយមីងឈប់ដែរ?

ខ៖  បងប្អូនជាអ្នកអោយឈប់នឹង ពីព្រោះអីគេគ្មានលទ្ធភាពទិញកងអោយជិះទៅរៀនទេនឹង

ក៖  អ៎ូ!ចឹងហោសមីង?

ខ៖ ដល់ពេលចឹងទៅយំដេកយំចឹងដល់ពេលម្តាយធំគាត់អាណិតទៅមកនៅបានតែមួយឆ្នាំនឹង គេក៏បាន រៀបការអោយតែម្តងនឹងទៅណាស់

ក៖  ចឹងមានន័យថាមិនមែនចង់ឈប់ខ្លួនឯងទេ ប៉ុន្តែមីងចង់រៀនតទៀតដែរនឹង?

ខ៖ ចង់រៀនត ប៉ុន្តែដូចថាបងប្អូនក្រ

ក៖  ដោយសារតែកាលៈទេសៈចឹង?

ខ៖  ខ្ញុំរៀនបានតែត្រឹមថ្នាក់ទី4នឹង

ក៖ ចុះបើចង់អោយកូនផ្តែផ្តាំទៅកូនចៅជំនាន់ក្រោយៗតើមីងចង់ផ្តែផ្តាំអីទៅពួកគាត់ដែរមីង?

ខ៖  អោយប្រឹងរៀនទៅអោយមានការងារចេះដឹងជាងខ្ញុំនឹង

ក៖
ចុះបើចង់អោយពួកគាត់ជៀសវៀងវិញតើមីងចង់អោយពួកគាត់ជៀសវៀងអីគេដែរមីង?

ខ៖  ជៀសវៀងលួចនឹងថ្នាំញៀនអីនឹងអោយជៀសអោយផុតនឹង កុំអោយមានចឹងនឹង

ក៖  បាទចឹងមានអីផ្សេងទៀតទេមីង?

ខ៖  ផឹកនឹងល្បែងអីនឹងអោយជៀសទៅណាស់ ធ្វើម៉េចអោយតែធ្វើផ្លូវល្អណាស់

ក៖  ចឹងជាចុងក្រោយខ្ញុំអរគុណច្រើនមីងដែរមីងបានអោយខ្ញុំសំភាសន៍ពីប្រវត្តិរបស់មីង
ហើយខ្ញុំនឹងដាក់
ការសំភាសន៍មួយនេះទៅក្នុងវេបសាយរបស់សាលាដើម្បីតំកល់ទុកអោយមីងចឹងណាស់

ខ៖  ចា៎!នឹងហើយ

ក៖  បាទចឹងអរគុណច្រើនមីង៕៕៕